ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ២៧៤ សសរ.កសក

# សេចក្ដីសម្រេច
# ស្ដីពី
# ការបង្កើតគណៈកម្មការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៨ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហគមន៍កសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្ដីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើរដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋានការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤ ស្ដីពីការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មចំណុះអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ២២០ ប្រក.កសក.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរកសិកម្មរាជធានី ខេត្ត



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

- បានឃើញប្រកាសលេខ០៩០ ប្រក.កសក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម
- បានឃើញប្រកាសលេខ ៦០៩ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្ម រាជធានី ខេត្ត និងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើនិងខណ្ឌរដ្ឋបាលជលផលឱ្យស្ថិតក្រោមមន្ទីរកសិកម្ម រាជធានី ខេត្ត
- បានឃើញប្រកាសលេខ១៦៨ ប្រក.កសក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការបង្កើតនិងចុះបញ្ជីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

### ប្រការ ១.-

ត្រូវបានបង្កើតគណៈកម្មការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ដែលមានសមាសភាពដូចរាយនាមខាងក្រោមៈ

| | | |
|---|---|---|
| ១- ឯកឧត្តម ង៉ិន ឆាយ | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកសិកម្ម | ប្រធាន |
| ២- លោក ស្រ៊ិន សុខុម | អគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- លោក ជា សាំងជូណា | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម | អនុប្រធាន |
| ៤- លោក ទី សុង | ប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ នៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៥- លោក អ៊ុត សំអាល់ | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៦- លោកស្រី វង្ស ផល្លា | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិកា |
| ៧- លោក អ៊ុក សារឿន | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៨- លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទាំង២៥ | | សមាជិក |
| ៩- លោក គង់ ពិសិដ្ឋ | ប្រធានការិយាល័យចុះបញ្ជី និងជំរុញសហគមន៍កសិកម្ម នៃនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម | សមាជិក |
| ១០- លោក ស៊ឹម ប៊ូរ៉ាំមី | ប្រធានការិយាល័យនីតិកម្ម និងដោះស្រាយវិវាទសហគមន៍កសិកម្ម នៃនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម | សមាជិក |
| ១១- លោក ធួន សាន្ត | តំណាងសហភាពសហគមន៍កសិកម្ម | សមាជិក |
| ១២- លោក ឆេង ចុង | តំណាងសហគមន៍កសិកម្ម | សមាជិក |
| ១៣- កញ្ញា កង សុភាព៉ា | អនុប្រធានការិយាល័យនីតិកម្ម និងដោះស្រាយវិវាទសហគមន៍កសិកម្ម នៃនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម | លេខាធិការ។ |

### ប្រការ ២.-

គណៈកម្មការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាខាងលើនេះ អាចជ្រើសរើសមន្ត្រីបន្ថែមតាមការចាំបាច់ និងមានភារកិច្ចដូចតទៅៈ

- រៀបចំឯកសារចាំបាច់សម្រាប់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាដែលត្រូវបង្កើតដើម្បីដាក់ឆ្លងមហាសន្និបាតកំណើតដំបូង
- កោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- រៀបចំនិងដាក់ពាក្យស្នើសុំការយល់ព្រម និងចុះបញ្ជីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជានៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម
- សហការជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ដើម្បីកៀងគរថវិកាសម្រាប់ដំណើរការបង្កើត និងចុះបញ្ជីសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា
- បូកសរុបលទ្ធផលនៃដំណើការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាខាងលើ និងរាយការណ៍ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលឯកឧត្តមរដ្ឋមន្ត្រីប្រគល់ជូន ដើម្បីឱ្យការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាទទួលបានជោគជ័យ។

**ប្រការ៣ .-**

អនុប្រធានអចិន្ត្រៃយ៍ អនុប្រធាន សមាជិក សមាជិកា និងលេខាធិកា នៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានគណៈកម្មការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជានេះមានសិទ្ធិអញ្ជើញបន្ត្រីពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ៤ .-**

គណៈកម្មការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជានេះ ត្រូវបំពេញតួនាទីជាគណៈកម្មការបំពេញកិច្ច ដែលត្រូវបំពេញភារកិច្ចរបស់ខ្លួនចាប់ពីដំណាក់កាលចាប់ផ្តើមការរៀបចំបង្កើតសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា ហើយត្រូវរំលាយទៅវិញជាស្វ័យប្រវត្តិ នៅពេលដែលសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជាត្រូវបានចុះបញ្ជីជាផ្លូវការ។

**ប្រការ៥ .-**

អគ្គលេខាធិការ អគ្គាធិការ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួលៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ នេសាទ
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ